ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស
អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ
លេខ…………………………………….

# របាយការណ៍

## បូកសរុបលទ្ធផលការងារប្រចាំខែសីហា ឆ្នាំ២០២២

**ក-អំពីកម្លាំង៖**

សរុបបរួមចំនួន៖ ០៥នាក់ (ស្រី០២នាក់) អវត្តមាន៖ ០០

**ខ-សកម្មភាព និងលទ្ធផលការងារ**

ខ.១-កិច្ចប្រជុំពង្រឹងកិច្ចសហប្រតិបត្តិការ ការកសាងគោលនយោបាយ និងបទដ្ឋានគតិយុត្តិនានា

<u>សកម្មភាពក្នុងស្រុក</u>

- **ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង បានអញ្ជើញចូលរួមក្នុងជំនួបរវាង គ.ជ.ប.ជ ដែលដឹកនាំដោយលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ និងតំណាងបេសកកម្មរបស់អង្គការ JICA ដឹកនាំដោយ លោកស្រី យូឈីកាវ៉ា តូម៉ូមី (Uchikawa Tomomi) ប្រធានជាន់ខ្ពស់នៃការិយាល័យលើកកម្ពស់សមភាពយេនឌ័រ និងកាត់បន្ថយភាពក្រីក្រ និងជាប្រធានដឹកនាំការអនុវត្ត គម្រោង និងសហការីស្តីពីគម្រោងផែនការសកម្មភាព នៃការអភិវឌ្ឍសមត្ថភាព ក្នុងការប្រឆាំង ការជួញដូរមនុស្ស របស់ JICA នៅបន្ទប់ប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ អញ្ជើញមានវត្តមានក្នុងជំនួប នោះរួមមាន លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ លោកស្រី វរសេនីយ៍ទោ ថោង សុវុត្ថិ អនុប្រធានក្រុមជំនួយ កិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ។

- **ថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២** លោកឧត្តមសេនីយ៍ត្រី អ៊ុន មាន ប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិជាតិ អន្តរជាតិ និងលោកស្រី វរសេនីយ៍ត្រី ថោង សុវត្ថិ អនុប្រធានក្រុម បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាស្តីពីការត្រៀមការងារពិធីការសម្រាប់ ការរៀបចំទិវាជាតិអន្តរសាសនា លើកទី៦ ដឹកនាំកិច្ចប្រជុំដោយ លោកជំទាវ ឧត្តមសេនីយ៍ ឯកវេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ នៅក្នុងកិច្ចប្រជុំក្រុមការងារនៃគណៈកម្មាធិការរៀបចំបុណ្យជាតិ-អន្តរជាតិ ក្រុមការងារពិធីការក្រសួងមហាផ្ទៃ និងក្រុមការងាររៀបចំកម្មវិធី នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានព្រមព្រៀងគ្នាក្នុងការទទួលយកការងារតាមជំនាញទៅអនុវត្ត។

- **ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង បាន អញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាបន្តស្តីពី ការត្រៀមរៀបចំកម្មវិធីវេទិកាផ្សព្វផ្សាយអន្តរសាសនា ឆ្នាំ២០២២ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ សមាសភាពចូលរួមកិច្ចប្រជុំ មានលោកជំទាវឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ ជាអគ្គលេខាធិការរង ប្រធានលេខាធិការដ្ឋាន អនុប្រធាននៃក្រុមជំនួយកិច្ចការ មន្ត្រីពាក់ព័ន្ធ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អង្គការដៃគូរអភិវឌ្ឍ និងប្រធានទីភ្នាក់ងារជាតិអន្តរជាតិ។

- **ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២** លោកឧត្តមសេនីយ៍ត្រី អ៊ុន មាន ប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិការ ជាតិ និងអន្តរជាតិ និងជាអនុប្រធានក្រុមការងារព័ត៌មានវិទ្យា នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានបន្តវគ្គបណ្តុះបណ្តាលអក្ខរកម្មឌីជីថលស្តីពី៖ មូលដ្ឋានគ្រឹះ នៃការសរសេរកូដកម្មវិធី (HTML) ជូនដល់ក្រុមជំនួយកិច្ចការទាំង៦ និងក្រុមការងារលេខាធិការដ្ឋាន ក្នុងគោលបំណងដើម្បីពង្រឹងសមត្ថភាពដល់មន្ត្រីក្រោមឱវាទនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ គួររំលឹកផងដែលថា វគ្គបណ្តុះបណ្តាលជំនាញនេះធ្វើឡើងរយៈពេល៣ខែ ដែលបានចាប់ផ្តើមបើកវគ្គដំបូងនៅដើមខែកក្កដាកន្លងមក។ សមាសភាពចូលរួមមាន លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ និងជាប្រធានក្រុមការងារព័ត៌មានវិទ្យា លោកឧត្តមសេនីយ៍ត្រី អ៊ុន មាន ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ និងជាអនុប្រធានក្រុមការងារព័ត៌មានវិទ្យា ជាគ្រូឧទ្ទេសក៍ លោកឧត្តមសេនីយ៍ត្រី យឹម សំណាង អនុប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ លោកវរសេនីយ៍ត្រី សោម ស៊ីវីន លោកវរសេនីយ៍ត្រី ធន ដារ៉ារិទ្ធ លោកវរសេនីយ៍ត្រី រ៉ន សុភ័ក្ត្របញ្ញា នាយរងការិយាល័យនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដែលមានចំនួនសរុប៦រូប (ស្រី០១រូប)។

- **ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ សហការជាមួយអង្គការយូនីសេហ្វ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី៖ កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំសាលាក្រុងព្រះសីហនុ។ សមាសភាពគណៈអធិបតីរួមមាន លោកជំទាវ ហៀក ហ៊ីមុល្លី អភិបាលរងខេត្ត លោកស្រីឧត្តមសេនីយ៍ត្រី ប៉ែន បញ្ញា ស្នងការរងនគរបាលខេត្ត លោកស្រី សៅ កាន ប្រធានមន្ទីរកិច្ចការនារី លោកស្រី ចាន់ កញ្ញា តំណាងអង្គការយូនីសេហ្វ UNICEF លោកជំទាវឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង ក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ និងអន្តរជាតិ លោកស្រីតំណាងពីនាយកដ្ឋានប្រឆាំងការជួញដូររបស់ក្រសួងសង្គមកិច្ច។ សមាសភាពអញ្ជើញ ចូលរួមក្នុងកិច្ចប្រជុំរួមមាន អភិបាលរង របស់រដ្ឋបាលក្រុងកោះរ៉ុង ប្រធានគ.ក.ន.ក សាលាក្រុងមន្ត្រី លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ត្រីរដ្ឋបាលសាលាក្រុង សុខាភិបាលស្រុកប្រតិបត្តិ នគរបាលនៃវព្រំដែនទឹក មន្ត្រីក្រុមការងារជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និង សហការីអង្គការយូនីសេហ្វ។

- **ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២២** លោកឧត្តមសេនីយ៍ត្រី អិុន មាន ប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិអន្តរជាតិបានអញ្ជើញចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញស្តីពី "ការអនុវត្តគោលការណ៍មិនដាក់ពិន័យទោសទៅលើជនល្មើសទាំងឡាយណា ដែលជាជនរងគ្រោះក្នុងអំពើជួញដូរមនុស្ស ក្នុងក្របខណ្ឌអាស៊ាន"។ កិច្ចប្រជុំបានធ្វើការពិភាក្សាទៅលើប្រធានចំនួនពីរគឺ ទាក់ទងនឹងបញ្ហាប្រឈមក្នុងការ កំណត់អត្តសញ្ញាណជនរងគ្រោះដែលបានប្រព្រឹត្តបទល្មើស និងការស្វែងរកដំណោះស្រាយដើម្បីជួយសង្គ្រោះ។ ការកំណត់អំពី បញ្ហានៃជនរងគ្រោះនៃការជួញដូរ អាចជាប់ពាក់ព័ន្ធក្នុងសកម្មភាពខុសច្បាប់ជាច្រើន ពីការធ្វើអន្តោប្រវេសន៍និងបទល្មើសទាក់ទងនឹងឯកសារ តាមរយៈបទល្មើសដែលទាក់ទងនឹងអំពើពេស្យាចារ (នៅក្នុងប្រទេសដែល មានសេវាផ្លូវភេទខុសច្បាប់) ឬការនេសាទខុសច្បាប់ ឬបទល្មើសទាក់ទងនឹងការងារផ្សេងទៀត។ កិច្ចប្រជុំដឹកនាំដោយក្រុមការងារ PROSPECT ASEAN សហការដោយ ASEAN-ACT និង USAID ដែលមាន សមាសភាពចូលរួមប្រមាណ ២៥រូប។

- **ថ្ងៃទី៨-៩ ខែសីហា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញជាអធិបតីភាព ក្នុងពិធីបិទវគ្គបណ្តុះបណ្តាលសម្រាប់ក្រុមទី១ ស្តីពី "កិច្ចការពារកុមារ និង ការកំណត់អត្តសញ្ញាណ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន - Training on Child Protection and Identification of Human Trafficking and Abuse" ។ វគ្គបណ្តុះបណ្តាលនេះរៀបចំ ឡើងក្រោមកិច្ចសហការរវាង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអង្គការយូនីសេហ្វ ក្នុងគោលបំណងដើម្បីផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ និងពង្រឹងសមត្ថភាព ដល់មន្ត្រីពាក់ព័ន្ធដែលអនុវត្តផ្ទាល់នៅមូលដ្ឋានសរុបចំនួន ៥២រូប(ស្រី២០រូប)អញ្ជើញមកពីក្រុងព្រះសីហនុ និងក្រុងកោះរ៉ុងក្នុងចំណោម អ្នកចូល រួមសរុប ៦១រូប (ស្រី២៦រូប) ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារ ការបញ្ជូនករណីកុមាររងគ្រោះ និងងាយរងគ្រោះទៅកាន់សេវាសមស្របដើម្បីជានាការការពារ និងសុខមាលភាពរបស់ កុមារដែលទទួលរងផលប៉ះពាល់ពីចំណាកស្រុក។ ចូលរួមជាគ្រូឧទ្ទេសរួមមាន លោកជំទាវ ឧត្តមសេនីយទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង ក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិនិងអន្តរជាតិ, លោកឧត្តមសេនីយ៍ទោ កែវ ផល្លា ប្រធានក្រុម ជំនួយកិច្ចការយុត្តិធម៌, លោកស្រីវរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ និងអន្តរជាតិ, លោកស្រី ចាន់ កញ្ញា តំណាងអង្គការយូនីសេហ្វ, លោកស្រី កែវ ម៉ាលី ទីប្រឹក្សាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង លោកគ្រូ ស៊ាង លាភ អ្នកប្រឹក្សាចិត្តសាស្ត្រ នៃអង្គការធីភីអូ និងលោកអនុសេនីយ៍ឯក ហុក ដារី មន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាអ្នកសម្របសម្រួលកម្មវិធី។

- **ថ្ងៃទី១០-១១ ខែសីហា ឆ្នាំ២០២២** លោកឧត្តមសេនីយ៍ត្រី អិុន មាន ប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិការអន្តរជាតិ ក្នុងនាមលោកជំទាវឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង និងជា ប្រធានផែនការងារប្រឆាំងការជួញដូរមនុស្សនៃ SOMTC-CAMBODIA ជាតំណាង **ឯកឧត្តមនាយឧត្តមសេនីយ៍ ប៉ោ ភក្តិ** អគ្គ

លេខាធិការ និងជាប្រធានក្រុមការងារ SOMTC ប្រចាំកម្ពុជា បានអញ្ជើញចូលរួម កិច្ចប្រជុំស្តីពី “កិច្ចប្រជុំអន្តរវិស័យអាស៊ាន ស្តីពីផែនការ ការងារពហុវិស័យ ប្រឆាំងការជួញដូរមនុស្ស ឆ្នាំ ២០២២ - ២០២៧” ដែលបានរៀបចំឡើងដោយប្រទេសហ្វីលីពីន តាមរយៈប្រព័ន្ធវីដេអូពីចម្ងាយរយៈពេល២ថ្ងៃ ពីថ្ងៃទី១០ ដល់ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២។ នៅក្នុងកិច្ចប្រជុំពិភាក្សា លោកឧត្តមសេនីយ៍ត្រី អ៊ុន មាន តំណាងឱ្យSOMTC កម្ពុជា ដែលស្ថិតនៅក្នុងចង្កោមស្ថាប័នពាក់ព័ន្ធ ទៅតាមវិស័យអាស៊ាន (ASEAN Sectoral Bodies) បានធ្វើ បទបង្ហាញខ្លីទាក់ទងនឹងការសង្ខេបអំពី សកម្មភាពផែនការការងារទាក់ទង នឹងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ ក្នុងនោះយើងបានធ្វើការស្នើសុំ និងចូលរួមក្នុងកិច្ចពិភាក្សាដោយស្នើឱ្យមានការបង្កើតឡើងជា របាយការណ៍ស្តង់ដាគម្រូមួយ ដើម្បីប្រើប្រាស់ជាប្រយោជន៍រួម។ ខ្លឹមសារនៃកិច្ចប្រជុំបានផ្តោតសំខាន់ទៅលើការ បង្កើតគម្រោងផែនការយុទ្ធសាស្ត្រ Bohol Work Plan (ជំនាន់ទី២) ដែលមានការដឹកនាំ និងចូលរួម ដោយស្ថាប័នអាស៊ាន ទៅតាមវិស័យនីមួយៗ ដែលជាមធ្យោបាយឆ្ពោះទៅរកការអនុវត្តទាំងផែនការ សកម្មភាព ACTIP និង អាស៊ានប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (APA)។ ផែនការការងារ Bohol TIP ដែលបានដឹកនាំបង្កើតឡើងដោយ SOMTC ហ្វីលីពីន នៅក្នុងឆ្នាំ២០១៦ តាមរយៈកិច្ចខិតខំ ប្រែងរួមគ្នា។ ផែនការការងារនេះស្វែងរកការសម្របសម្រួលនៃកិច្ច ខិតខំប្រឹងប្រែងរបស់ អាស៊ាន និងថ្នាក់ ជាតិក្នុងការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពក្នុងការប្រឆាំងការជួញដូរមនុស្ស (TIP) ការពារ និងគាំទ្រ ជនរងគ្រោះ ពង្រឹងការជួញដូរ និងច្បាប់ពាក់ព័ន្ធកាត់ទោសជនល្មើស បង្កើនកិច្ចសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិក្នុងការប្រឆាំងនឹងការប្រឆាំងការជួញដូរមនុស្សស្របតាម ACTIP និងAPA ។ សកម្មភាពដែល ធ្វើឡើងដោយអនុលោមតាម ផែនការការងារនេះនឹងត្រូវបានគាំទ្រដោយ គោលការណ៍ស្នូលមានដូចជា៖ វិធីសាស្ត្រផ្អែកលើសិទ្ធិ និងមជ្ឈមណ្ឌលជនរងគ្រោះ, ការមិនធ្វើបាប, ការមិនដាក់ទណ្ឌកម្ម, ការមិនរើសអើង, ចំណាប់អារម្មណ៍ល្អបំផុតរបស់កុមារ, សមភាពយេនឌ័រ, និងការរួមបញ្ចូលសង្គម។ ផែនការការងារនេះត្រូវបានកសាងឡើង នៅជុំវិញសសរស្តម្ភទាំងបួននៃ APA រួមមាន៖ ការទប់ស្កាត់ TIP, ការការពារជនរងគ្រោះ, ការអនុវត្តច្បាប់ និងការកាត់ទោសឧក្រិដ្ឋកម្មនៃ TIP, កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលក្នុងតំបន់ និងអន្តរជាតិ ។

- **ថ្ងៃទី១០-១១ ខែសីហា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានអញ្ជើញជាគណៈអធិបតី ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពី “កិច្ចការពារកុមារ និង ការកំណត់អត្តសញ្ញាណ ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និង ការរំលោភបំពាន -Training on Child Protection and Identification of Human Trafficking and Abuse” សម្រាប់ក្រុមទី២។ អញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីបើកវគ្គ មានលោកជំទាវ ហៀក ហ៊ីមុល្លី អភិបាលរង និង ជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ លោកស្រី កែវ ម៉ាលី ទីប្រឹក្សា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងនីតិសម្បទា លោកស្រី ចាន់ កញ្ញា មន្ត្រីសម្របសម្រួលគម្រោង តំណាងអង្គការ យូនីសេហ្វ និងលោក ស៊ាង លាប អ្នកជំនាញចិត្តសាស្ត្រ អង្គការជីភីអូកម្ពុជា។ វគ្គបណ្តុះបណ្តាលនេះរៀបចំឡើង ក្រោមកិច្ចសហការរវាង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និង អង្គការយូនីសេ

ហ្វ ដែលដឹកនាំ និង សម្របសម្រួលដោយ លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង ក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ និងអន្តរជាតិ ដែលធ្វើឡើងក្នុង គោលបំណងផ្សព្វផ្សាយឱ្យបាន កាន់តែទូលំទូលាយ និងពង្រឹងសមត្ថភាព ដល់មន្ត្រីពាក់ព័ន្ធ ដែលអនុវត្តផ្ទាល់នៅមូលដ្ឋានសរុបចំនួន ៥២រូប (ស្រី១៤រូប) អញ្ជើញមកពីស្រុកព្រៃនប់ ក្នុងចំណោមអ្នក ចូលរួមសរុប ៦០រូប(ស្រី១៨រូប) ក្នុងការកំណត់ អត្តសញ្ញាណជនរងគ្រោះជាពិសេសស្ត្រី និងកុមារ ការបញ្ជូន ករណីកុមាររងគ្រោះ និងងាយរងគ្រោះទៅកាន់ សេវាសមស្រប ដើម្បីជានាការការពារ និងសុខមាលភាព របស់កុមារ ដែលទទួលរងផលប៉ះពាល់ពីចំណាកស្រុ ក។ អញ្ជើញចូលរួមជាគ្រូឧទ្ទេសរួមមាន លោកជំទាវ ឧត្តមសេនីយទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង ក្រុម ជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ, លោកឧត្តមសេនីយទោ កែវ ផល្លា ប្រធានក្រុម ជំនួយកិច្ច ការយុត្តិធម៌, លោកស្រីវរសេនីយ៍ទោ ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិការជាតិ និងអន្តរ ជាតិ, លោកស្រី ចាន់ កញ្ញា តំណាងអង្គការ យូនីសេហ្វ, លោកស្រី កែវ ម៉ាលី ទីប្រឹក្សា នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង លោកគ្រូ ស៊ាង លាប អ្នកប្រឹក្សាចិត្តសាស្ត្រ នៃ អង្គការជីភីអូ និង លោក អនុសេនីយ៍ឯក ហុក ដារី មន្ត្រីនៃ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាអ្នកសម្របសម្រួលកម្មវិធី។ អញ្ជើញជាគ ណៈអធិបតីក្នុងពិធីបិទវគ្គសម្រាប់ ក្រុមទី២ លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ និងលោកជំទាវ ហៀក ហ៊ីមុល្លី អភិបាលរង ក៏បានផ្តាំផ្ញើដល់សិក្ខាកាម ឱ្យយកចំណេះដឹងដែលបាន សិក្សា ក្នុងវគ្គនេះទៅផ្សព្វផ្សាយ ដើម្បីឱ្យប្រជាជនចាត់ទុកថា រឿងជួញដូរមនុស្សជារឿងរបស់ខ្លួន មិនមែនរឿង នរណាម្នាក់ដែលត្រូវដោះស្រាយ រាយការណ៍ក្រោយការអង្កេតបឋម ឬបានដឹងថានរណាម្នាក់អាចជាជនរង គ្រោះ ដោយអំពើកេងប្រវ័ញ្ចរំលោភ បំពានជួញដូរផ្លូវភេទ និងជួញដូរមនុស្ស។ សូមរួមគ្នាទប់ស្កាត់ និងលុប បំបាត់អំពើជួញដូរមនុស្ស នៅក្នុង ព្រះរាជាណាចក្រកម្ពុជា។

- **ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២** លោកឧត្តមសេនីយ៍ត្រី អ៊ុន មាន ប្រធានក្រុមជំនួយកិច្ចការ សហប្រតិបត្តិ ការជាតិ អន្តរជាតិ លោកវរសេនីយ៍ត្រី ឆន ដារ៉ារិទ្ធ នាយរងការិយាល័យ បានអញ្ជើញចូលរួមក្នុង កិច្ចប្រជុំឆ្លង របាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅ អនុវត្តបន្ត ឆមាសទី២ ឆ្នាំ២០២២ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ។ អញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ តំណាងក្រសួង-ស្ថាប័នទាំង៦ និងក្រសួង-ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ មានឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធានគ.ជ.ប.ជ ទទួលបន្ទុកការងារទេសន្តរ ប្រវេសន៍ លោកជំទាវ វេជ្ជ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី អនុប្រធាន គ.ជ.ប.ជ ទទួលបន្ទុកការងារ សហប្រតិបត្តិការជាតិ អន្តរជាតិ ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុប្រធានគ.ជ.ប.ជ ទទួលបន្ទុកក្រុមការងារជួយជនរងគ្រោះ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ទទួលបន្ទុកក្រុមការងារអនុវត្តច្បាប់ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ឯកឧត្តម លោកជំទាវ ជារដ្ឋលេខាធិការ

អនុរដ្ឋលេខាធិការ តំណាងពីក្រសួងអប់រំយុវជនកីឡា ក្រសួងយុត្តិធម៌ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ក្រសួងវប្បធម៌ ក្រសួងព័ត៌មាន ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លោកជំទាវ អគ្គស្នងការរង នៃស្នងការដ្ឋាន នគរបាលជាតិ ឯកឧត្តម អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋាន អន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ឯកឧត្តម លោកជំទាវ ជាអគ្គលេខាធិការរង ប្រធាន លេខាធិការដ្ឋាន និងមន្ត្រីពាក់ព័ន្ធនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ប្រធាន អនុប្រធាន នាយកដ្ឋាន នៃក្រសួងស្ថាប័នពាក់ព័ន្ធ។

- **ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ លោកស្រី វរសេនីយ៍ទោ ថោង សុវត្ថី អនុប្រធានក្រុមកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ បានទទួល ការអនុញ្ញាតចូលជួបពិភាក្សាការងារជាមួយ កញ្ញា Kristen Scharf អ្នកគ្រប់គ្រងរបស់អង្គការ A២១ ប្រចាំប្រទេសកម្ពុជា លោក រស់ យ៉េង ប្រធានមជ្ឈមណ្ឌល តស៊ូមតិសម្រាប់កុមារ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។ កិច្ចពិភាក្សានោះផងដែរ ក៏មានការអញ្ជើញចូលរួមពី លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ។ នៅក្នុងជំនួបពិភាក្សាការងារនេះមាន គោលបំណង សិក្សាអំពីយុទ្ធនាការផ្សព្វផ្សាយ និងកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាសកលរបស់អង្គការ A21 ដែលមានចំណងជើងថា "Can You See Me?"។ យុទ្ធនាការនេះព្យាយាមធ្វើឱ្យសាធារណជនស្គាល់ពីបរិយាកាសនៃការកេងប្រវ័ញ្ចទូទៅដោយបង្ហាញពីជីវិត ពិតរបស់ជនរងគ្រោះ នៃទាសភាព សម័យទំនើប។ យុទ្ធនាការនេះត្រូវបាន អប់រំដល់អ្នកទស្សនាពីប្រភេទនៃការជួញដូរមនុស្សដែលអាចកើតនៅក្នុងសហគមន៍មូលដ្ឋាន។

- **ថ្ងៃទី២៥-២៦ ខែសីហា ឆ្នាំ២០២២** លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីលក្ខិណា អគ្គលេខាធិការរង បានអញ្ជើញអមដំណើរ គណៈប្រតិភូនៃប្រទេសកម្ពុជាដែលជាសមាជិកនៃ គ.ជ.ប.ជ ដើម្បីចូលរួមកិច្ចប្រជុំទ្វេភាគី រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ស្តីពីការពិនិត្យមើលនីតិវិធីប្រតិបត្តិស្តង់ដាស្តីពីកិច្ចសហប្រតិបត្តិការនៃការអនុវត្តច្បាប់រវាងប្រទេសថៃ-កម្ពុជា នៅសណ្ឋាគារ Sukosol ទីក្រុងបាងកក ប្រទេសថៃ ដែលបានសហការរៀបចំឡើងពីអង្គការអោយអុអឹម IOM។ សមាសភាពនៃប្រតិភូ ព្រះរាជាណាចក្រកម្ពុជាមានថ្នាក់ដឹកនាំពីអន្តរក្រសួង-ស្ថាប័ន មាន **លោកជំទាវ ជូ ប៊ុនអេង** អនុប្រធាន អចិន្ត្រៃយ៍ គ.ជ.ប.ជ ជាប្រធានគណៈប្រតិភូ ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច ក្រសួងការបរទេសសហប្រតិបត្តិការអន្តរជាតិ ក្រសួងកិច្ចការនារី អគ្គលេខាធិការ និង អគ្គលេខាធិការរង ទទួលបន្ទុកការងារសហប្រតិបត្តិការជាតិ អន្តរជាតិ និងអនុវត្តច្បាប់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គស្នងការរងទទួលបន្ទុកការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិអគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ប្រធាននៃក្រុមជំនួយកិច្ចការយុត្តិធម៌ នៃ គ.ជ.ប.ជ អង្គការដៃគូពាក់ព័ន្ធ មាន ប្រធានបេសកកម្ម និងសហការីរបស់អង្គការ IOM ប្រចាំកម្ពុជា, អង្គការ IJM, អង្គការ ASIAN ACT ។ សមាស

ភាពនៃរាជរដ្ឋាភិបាលប្រទេសថៃ  មានតំណាងពីក្រសួងការងារ  និងកិច្ចការសង្គម  តំណាងស្ថាប័នកិច្ចការអ្នកច្បាប់ ក្រុមការងារបច្ចេកទេសពាក់ព័ន្ធ ការអនុវត្តច្បាប់ និង អង្គការដៃគូ មាន IOM ប្រចាំប្រទេសថៃ។

**ខ.២-ការងារចងក្រងព័ត៌មានតាមគេហទំព័រសារព័ត៌មាននានា (មានឆ្លាប់ក្នុងខួបសម្ព័ន្ធ)**

- <u>គ្រោះថ្នាក់ ឬហានិភ័យការងារក្នុងប្រទេសគោលដៅ</u>
  - ឧបទ្ទវហេតុ 00 នាក់
  - ពលករសរុប 00 នាក់
- <u>ប្រព្រឹត្តបទល្មើសនៅនឹងកន្លែង</u>
  - ចាប់ខ្លួន 00 នាក់
  - ពលករសរុប 00 នាក់
- <u>ពលកររួចទោសពីពន្ធនាគារ</u>
  - ពលករសរុប 00 នាក់
- <u>ពលករចំណាកស្រុកខុសច្បាប់</u>
  - បញ្ជូនត្រឡប់   **១៣៨នាក់**
  - ចាប់ខ្លួន   00នាក់
  - ពលករសរុប   **១៣៨នាក់**

**គ-ទិសដៅបន្ត**

- បណ្តុះបណ្តាលជំនាញមូលដ្ឋានបច្ចេកទេសសរសេរប្រូក្រាមដល់ក្រុមការងារព័ត៌មានវិទ្យាថ្មី
- បណ្តុះបណ្តាលគ្រូបង្គោលនៅមណ្ឌលទទួលពលករកំរៀង

ថ្ងៃ                    ខែ              ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី              ខែ               ឆ្នាំ ២០២២

**ប្រធាន**

**ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ**